ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥២ សសរ

សេចក្តីសំរេច
ស្តីពី
ការរៀបចំកិច្ចប្រជុំ នៃក្រុមពិគ្រោះយោបល់លើកទី ៦

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ / អនក្រ . បក / ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧០ / អនក្រ . បក / ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំ និងសំរបសំរួលការងារត្រៀមរៀបចំ សំរាប់កិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ៦ ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ ២០០២ ខាងមុខនេះ ។

ប្រការ ២ : ក្នុងក្របខ័ណ្ឌនៃការដឹកនាំ និងសំរបសំរួលការងាររៀបចំសំរាប់កិច្ចប្រជុំនេះ ឯកឧត្តម គាត ឈន់ ត្រូវសហការជាមួយថ្នាក់ដឹកនាំនៃបណ្តាក្រសួង និងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ អោយចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែង ពិគ្រោះយោបល់ជាមួយតំណាងប្រទេស និងអង្គការអន្តរជាតិអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់នានា ។

www.pheakdeylaw.com

ប្រការ ៣ : ឯកឧត្តម គាត ឈន់ ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូននាយករដ្ឋមន្ត្រី អំពីលទ្ធផលនៃការងារដែលបានបំពេញ ហើយត្រូវរៀបចំឯកសារចាំបាច់នានា សំរាប់កិច្ចប្រជុំលើកទី ៦ នេះ ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីពិនិត្យ ផ្តល់យោបល់ណែនាំ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

ប្រការ ៤ : ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម គាត ឈន់ ប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (គអក / គជនា) ដែលមានឯកឧត្តម ឈៀង យ៉ាណារ៉ា ជាអគ្គលេខាធិការសំរាប់ជំនួយការងារប្រចាំថ្ងៃ ។

ប្រការ ៥ : សេចក្តីសំរេចនេះមានប្រសិទ្ធភាពរហូតដល់កិច្ចប្រជុំលើកទី ៦ នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម គាត ឈន់ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦ " ដើម្បីអនុវត្ត "*
- *ឯកសារ- កាលប្បវត្តិ*

www.pheakdeylaw.com